**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**
លេខៈ ០០៦ .............. គ ម ក.ប្រក

# ប្រកាស
## ស្តីពី
## ខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់
## ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១០

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
Phone : 855-23-885-611
: 855-23-885-622
E-mail : info@secc.gov.kh

Downloaded from http://www.khmerlaws.com

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-** គោលបំណង

ប្រកាសនេះមានគោលដៅកំណត់នូវ ខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ ដោយអនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-** និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ៖

-ច្បាប់ (Law) សំដៅដល់ច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-អនុក្រឹត្យ (Anukret) សំដៅដល់អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-វិធានប្រតិបត្តិការ (Operating Rules) សំដៅដល់វិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ។ វិធានប្រតិបត្តិការមានចែងនូវវិធាននិងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការ របស់ប្រតិបត្តិករនីមួយៗ វិធាននិងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាពនិងការចូលរួមក្នុងទីផ្សារ និងលក្ខន្តិកៈរបស់ប្រតិបត្តិករនីមួយៗ។ វិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រមានចែងបន្ថែមនូវវិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ។

-កិច្ចព្រមព្រៀងសេវា (Service agreement) សំដៅដល់កិច្ចព្រមព្រៀងនៃការផ្ដល់សេវាដែលរៀបចំធ្វើឡើងរវាងសមាជិកនិងអ្នកចូលរួមក្នុងទីផ្សាររបស់ប្រតិបត្តិករនីមួយៗ និងអតិថិជនរបស់ខ្លួន។



Downloaded from http://www.khmerlaws.com

## ជំពូកទី ២
## មាតិកាគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ

**ប្រការ ៣.-** វិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ

វិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ត្រូវចែងអំពី ÷

១-វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ទីផ្សារមូលបត្រ

២-វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព និងការចូលរួមក្នុងទីផ្សារ

៣-វិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ

៤-លក្ខន្តិកៈរបស់ប្រតិបត្តិករ។

**ប្រការ ៤.-** វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ទីផ្សារមូលបត្រ

វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ត្រូវចែងអំពីវិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការជួញដូរមូលបត្រ តាមប្រភេទនីមួយៗ។ វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការទាំងនេះ ត្រូវចែងជាអប្បបរមានូវ ÷

១-ពេលវេលានៃការជួញដូរ។

២-ប្រភេទនៃមូលបត្រដែលត្រូវធ្វើការជួញដូរ។

៣-ព័ត៌មានដែលត្រូវមានក្នុងការបញ្ជាទិញ-លក់។

៤-វិធីសាស្ត្រ និងយន្តការអនុវត្តការជួញដូរ។

៥-វិធានការក្នុងករណីដែលប្រព័ន្ធជួញដូរជួបប្រទះបញ្ហាជាយថាហេតុ។

៦-ព័ត៌មានដែលត្រូវផ្សព្វផ្សាយជាសាធារណៈទាក់ទងនឹងការជួញដូរ និងព័ត៌មានដែលប្រតិបត្តិករទីផ្សារមូលបត្រត្រូវជូនដំណឹងទៅសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

៧-កម្រៃប្រតិបត្តិការ និងកម្រៃផ្សេងទៀត។

៨-នីតិវិធីសម្រាប់ឃ្លាំមើលប្រតិបត្តិការជួញដូរ។

**ប្រការ ៥.-** វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាពនិងការចូលរួមក្នុងទីផ្សាររបស់ប្រតិបត្តិករទីផ្សារមូលបត្រ

វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព និងការចូលរួមក្នុងទីផ្សារ របស់ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវចែងជាអប្បបរមានូវ ÷



Downloaded from http://www.khmerlaws.com

១-ប្រភេទនៃសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

២-លក្ខខណ្ឌ និងនីតិវិធី ដើម្បីក្លាយជាសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

៣-លក្ខខណ្ឌ និងនីតិវិធី ដើម្បីល្បួរ ដកហូតសមាជិកភាព បញ្ឈប់មិនឱ្យចូលរួមក្នុងទីផ្សារ អនុញ្ញាតឱ្យចូលរួមជាថ្មីក្នុងទីផ្សារ ឬអនុញ្ញាតជាថ្មីជាសមាជិក។

៤-សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ដែលធានាបាននូវសមភាពរវាងសមាជិក និងអ្នកចូលរួមក្នុងទីផ្សារទាំងអស់។

៥-កាតព្វកិច្ចដែលតម្រូវឱ្យសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ គោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៦-និទ្ទេសដែលតម្រូវឱ្យសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ចែងនៅក្នុងកិច្ចព្រមព្រៀងសេវាដែលនឹងធ្វើជាមួយអតិថិជន។

៧-នីតិវិធីទាក់ទងនឹងការត្រួតពិនិត្យជាប្រចាំ និងដោយឥតព្រាងទុកនូវការអនុវត្តវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រដោយសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ពិសេសនីតិវិធីស្តីពីការធ្វើអធិការកិច្ចលើសកម្មភាពជួញដូរ និងលើស្ថានភាពហិរញ្ញវត្ថុរបស់សមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

៨-ពេលវេលា និងប្រភេទនៃព័ត៌មានដែលសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ត្រូវផ្តល់ដល់ប្រតិបត្តិករទីផ្សារមូលបត្រ។

៩-វិធានការខាងវិន័យ និងទណ្ឌកម្មចំពោះសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ដោយចែងឱ្យបានច្បាស់លាស់នូវមូលហេតុ និងប្រភេទនៃវិធានការដែលត្រូវអនុវត្ត ព្រមទាំងនីតិវិធីនៃការជូនដំណឹង។

១០-វិធានការដែលត្រូវចាត់ដោយសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ចំពោះអតិថិជនដែលធ្វើឱ្យការជួញដូរមិនបានសម្រេច។

១១-ប្រភេទសេវានានាដែលត្រូវផ្តល់ឱ្យសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ និងកម្រៃសេវាទាំងនោះ។

**ប្រការ ៦.-** វិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ

វិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ ត្រូវចែងជាអប្បបរមានូវ ÷

១-លក្ខខណ្ឌដើម្បីចុះបញ្ជីលក់មូលបត្រ។



Downloaded from http://www.khmerlaws.com

២-នីតិវិធីនៃការពិនិត្យពីលទ្ធភាពដែលអាចចុះបញ្ជីលក់មូលបត្រ។

៣-លក្ខខណ្ឌ និងនីតិវិធី ដើម្បីលុប និងដកចេញពីបញ្ជីលក់មូលបត្រ។

៤-កាតព្វកិច្ច និងនីតិវិធីនៃការផ្តល់ឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។

៥-ប្រភេទសេវានានាដែលត្រូវផ្តល់ឱ្យក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ និងកម្រៃសេវាទាំងនោះ។

## ជំពូកទី ៣

## មាតិកាគោលនៃវិធានប្រតិបត្តិការរបស់ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ

**ប្រការ ៧.-** វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ

វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រត្រូវចែងជាអប្បបរមានូវ ÷

១-ពេលវេលានៃការផាត់ទាត់ និងទូទាត់។

២-ចំណាត់ថ្នាក់ ឬប្រភេទនៃប្រតិបត្តិការដែលត្រូវផាត់ទាត់ និងទូទាត់។

៣-ការបើក និងការគ្រប់គ្រងគណនីផាត់ទាត់ និងទូទាត់មូលបត្រ។

៤-នីតិវិធីនៃប្រតិបត្តិការផាត់ទាត់ និងទូទាត់។

៥-វិធានសម្រាប់គ្រប់គ្រងការផ្ទេរកម្មសិទ្ធិ ផ្ទួរនឹងការទូទាត់សាច់ប្រាក់ ឬ ឌីវីភី (Delivery Vs. Payment - DVP)។

៦-ភាគរយនៃមូលបត្រ និងសាច់ប្រាក់ដែលសមាជិក និងអ្នកចូលរួមក្នុងទីផ្សារត្រូវមាននៅក្នុងគណនីរបស់ខ្លួន នៅពេលធ្វើប្រតិបត្តិការផ្ទេរមូលបត្រ និងទូទាត់សាច់ប្រាក់។

៧-នីតិវិធីនៃការផ្តល់របាយការណ៍អំពីប្រតិបត្តិការផាត់ទាត់និងទូទាត់ ឱ្យប្រតិបត្តិករទីផ្សារមូលបត្រ។

៨-វិធាន និងនីតិវិធីដែលត្រូវអនុវត្តនៅពេលដែលសមាជិក ឬអ្នកចូលរួម គ្មានលទ្ធភាព ឬអាចគ្មានលទ្ធភាពក្នុងការធ្វើប្រតិបត្តិការផាត់ទាត់និងទូទាត់។

៩-នីតិវិធីដែលត្រូវអនុវត្តនៅពេលប្រតិបត្តិការផ្ទេរមូលបត្រមិនបានសម្រេច ឬមូលបត្រដែលត្រូវផ្ទេរមិនបានចុះបញ្ជីត្រឹមត្រូវ។



Downloaded from http://www.khmerlaws.com

**ប្រការ ៨.-** វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព និងការចូលរួមក្នុងទីផ្សាររបស់ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ

វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព និងការចូលរួមក្នុងទីផ្សាររបស់ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវចែងជាអប្បបរមានូវ ៖

១-ប្រភេទនៃសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

២-លក្ខខណ្ឌ និងនីតិវិធី ដើម្បីក្លាយជាសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

៣-លក្ខខណ្ឌ និងនីតិវិធី ដើម្បីព្យួរ ដកហូតសមាជិកភាព បញ្ឈប់មិនឱ្យចូលរួមក្នុងទីផ្សារ អនុញ្ញាតឱ្យចូលរួមជាថ្មីក្នុងទីផ្សារ ឬអនុញ្ញាតជាថ្មីជាសមាជិក។

៤-សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ដែលធានាបាននូវសមភាពរវាងសមាជិក និងអ្នកចូលរួមក្នុងទីផ្សារទាំងអស់។

៥-ប្រភេទសេវានានាដែលត្រូវផ្តល់ឱ្យសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ និងកម្រៃសេវាទាំងនោះ។

៦-ប្រភេទព័ត៌មានដែលសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ត្រូវរក្សាទុក។

៧-លក្ខខណ្ឌដែលតម្រូវឱ្យសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ បង់វិភាគទានចូលមូលនិធិធានាការទូទាត់សង (Compensation Fund)។

៨-នីតិវិធីនៃការត្រួតពិនិត្យ ដឹកនាំកែតម្រង់ និងចាត់វិធានការខាងវិន័យ និងទណ្ឌកម្មនានាចំពោះសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ដែលមិនគោរពតាមវិធាន និងនីតិវិធី។

## ជំពូកទី ៤
## មាតិកាគោលនៃវិធានប្រតិបត្តិការរបស់សេវារក្សាទុកមូលបត្រ

**ប្រការ ៩.-** វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់សេវារក្សាទុកមូលបត្រ

វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់សេវារក្សាទុកមូលបត្រ ត្រូវចែងជាអប្បបរមានូវ ៖

១-ពេលវេលានៃការធ្វើប្រតិបត្តិការប្រចាំថ្ងៃ។

២-ការកំណត់ប្រភេទ ឬគុណវុឌ្ឍិមូលបត្រដែលអាចទទួលរក្សាទុក។

៣-ការបើក និងបិទគណនីរបស់អ្នកផ្ញើ។

៤-ការរៀបចំ និងការរក្សាទុកសៀវភៅគណនីរបស់អ្នកផ្ញើ។



Downloaded from http://www.khmerlaws.com

៥-ការដាក់ផ្ញើ ការដក និងការបង្វិលទៅវិញនូវមូលបត្រដែលដាក់ផ្ញើ។

៦-ការផ្ទេរមូលបត្ររវាងគណនី។

៧-នីតិវិធីនៃការគ្រប់គ្រង និងរក្សាទុកមូលបត្រដែលបានដាក់ផ្ញើ។

៨-នីតិវិធីនៃការអនុវត្តសិទ្ធិដែលទទួលបានពីមូលបត្រដែលដាក់ផ្ញើ។

៩-លក្ខខណ្ឌ និងនីតិវិធីនៃការបញ្ចាំមូលបត្រដែលដាក់ផ្ញើ។

**ប្រការ ១០.-** វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព ឬការចូលរួមក្នុងទីផ្សាររបស់សេវារក្សាទុកមូលបត្រ

វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព ឬការចូលរួមក្នុងទីផ្សាររបស់សេវារក្សាទុកមូលបត្រ ត្រូវចែងជាអប្បបរមានូវ ៖

១-ប្រភេទនៃសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ។

២-លក្ខខណ្ឌដើម្បីក្លាយជាសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ។

៣-លក្ខខណ្ឌ និងនីតិវិធី ដើម្បីព្យួរ ដកហូតសមាជិកភាព បញ្ឈប់មិនឱ្យចូលរួមក្នុងទីផ្សារ អនុញ្ញាតឱ្យចូលរួមជាថ្មីក្នុងទីផ្សារ ឬអនុញ្ញាតជាថ្មីជាសមាជិក។

៤-សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក ឬអ្នកចូលរួមក្នុងទីផ្សារដែលធានាបាននូវសមភាពរវាងសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារទាំងអស់។

៥-និទ្ទេសដែលតម្រូវឱ្យសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ ចែងនៅក្នុងកិច្ចព្រមព្រៀងសេវាដែលនឹងធ្វើជាមួយអតិថិជន។

៦-ប្រភេទសេវាដែលត្រូវផ្តល់ឱ្យសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ និងកម្រៃសេវាទាំងនោះ។

៧-នីតិវិធីនៃការត្រួតពិនិត្យ ដឹកនាំកែតម្រង់ និងចាត់វិធានការខាងវិន័យ និងទណ្ឌកម្មនានាចំពោះសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ ដែលមិនគោរពតាមវិធានប្រតិបត្តិការ និងនីតិវិធី។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ១១.-** បដិវាទកម្ម

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។



Downloaded from http://www.khmerlaws.com

**ប្រការ ១២.-** ការអនុវត្ត

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ២០១០

**គាត ឈន់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"

- គណៈកម្មការមូលបត្រកម្ពុជា
- ដូចប្រការ ១២

  "ដើម្បីអនុវត្ត"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com